# មគ្គុទេសក៍ណែនាំស្តីពីបរិយាបន្ន ការអប់រំ និងបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់ជនមានពិការភាព

## មគ្គុទេសក៍នៃបរិយាបន្នពិការភាពស្តីពី ការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) សម្រាប់ជនមានពិការភាព

ឆ្នាំ ២០២៣

# មាតិកា


មាតិកា ២
បុព្វកថា ៤
បញ្ជីអក្សរកាត់ ៦
ជំពូកទី១៖ ការស្វែងយល់អំពីពិការភាព ៧
១.១ គោលបំណង ៧
១.២ តើអ្វីទៅជាពិការភាព? ៧
១.៣ ផ្នត់គំនិតនៃពិការភាព ៧
១.៤ ប្រភេទសំខាន់ៗនៃពិការភាព ១០
២. ឧបសគ្គចំពោះបរិយាបន្នពិការភាព ១៨

ជំពូកទី២៖ ពិការភាព និងការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ក្នុងបរិបទកម្ពុជា ២០

ជំពូកទី៣៖ ការរួមបញ្ចូលជនមានពិការភាព នៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖ មគ្គុទេសន៍ឆ្ពោះទៅកាន់ បរិយាបន្នពិការភាព ២៦

៣.១. ការធ្វើផែនការបរិយាបន្ន ២៧
៣.២. លើកទឹកចិត្តឱ្យមានការចូលរួម ៣៤
៣.៣. ការកសាងសមត្ថភាព - ការកសាងការយល់ដឹង និងការទទួលយក ៣៦
៣.៤. ការបង្កលក្ខណៈងាយស្រួល និង ការសម្របសម្រួលសមរម្យ ៣៩
៣.៥. រក្សានូវភាពស្ថិតស្ថេរនិងនិរន្តភាពនៃបរិយាបន្ន ក្នុងរយៈពេលវែង ៥២
៣.៦. ដំណើរការចូលបម្រើការងារ ឬបង្កើតមុខរបរខ្លួនឯង ៥៣
ឧបសម្ព័ន្ធទី ១ បញ្ជីស្ថាប័នដែលធ្វើការលើពិការភាពនៅកម្ពុជា ៥៦
ឧបសម្ព័ន្ធ ២ ប័ណ្ណពិន្ទុបរិយាបន្នពិការភាព ៦១
ឧបសម្ព័ន្ធទី ៣ ទម្រង់ស្នើសុំការសម្របសម្រួល ៦២
ឯកសារយោង ៦៦

# បុព្វកថា

គោលការណ៍ណែនាំស្ដីពីបរិយាបន្នការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) សម្រាប់ជនមានពិការភាព (PwDs) បង្កើតឡើងក្នុងគោលបំណងផ្ដល់ជាការណែនាំដោយផ្អែកលើភស្តុតាង និងការអនុវត្តល្អៗ ទៅកាន់ស្ថាប័ននៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ក៏ដូចជាភាគីពាក់ព័ន្ធ ក្នុងការលើកកម្ពស់ និងអនុវត្តគោលនយោបាយបរិយាបន្ន នៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។ គោលការណ៍ណែនាំនេះផងដែរ ត្រូវបានបង្កើតឡើងដោយផ្អែកលើ អនុសាសន៍សំខាន់ៗ ដែលដកស្រង់ចេញពីកិច្ចប្រជុំក្រុមការងារបច្ចេកទេស (TWG) ស្ដីពីបរិយាបន្នការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលធ្វើឡើងមួយឆ្នាំម្ដង ចាប់តាំងពីក្នុងខែឧសភា ឆ្នាំ២០២២ និងឆ្នាំ២០២៣ ក៏ដូចជាមានការពិគ្រោះយោបល់បន្ថែមជាបន្តបន្ទាប់ ជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័ននៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ មួយចំនួនថែមទៀត។

គោលការណ៍ណែនាំនេះមានគោលបំណង ចងក្រងជាឯកសារដែលអាចកែសម្រួល និងធ្វើបច្ចុប្បន្នភាពតាមតម្រូវការ និងបរិបទដែលផ្លាស់ប្ដូររបស់ស្ថាប័ននៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងភាគីពាក់ព័ន្ធ។ គោលការណ៍ណែនាំនេះឆ្លុះបញ្ចាំងពី ការប្ដេជ្ញា ចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធានាថា ប្រជាពលរដ្ឋទាំងអស់ រួមទាំងជនមាន ពិការភាពទទួលបានសិទ្ធិក្នុងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាពស្មើៗគ្នា ដែលអាចឱ្យពួកគេអភិវឌ្ឍជំនាញ និងសមត្ថភាពសម្រាប់ការងារសមរម្យ និង បរិយាបន្នសង្គម។ វាក៏ស្របទៅតាមផែនការថ្នាក់ជាតិ និងអន្តរជាតិ ជាពិសេសស្ដង់ដារស្ដីពីសិទ្ធិជនមានពិការភាព ក៏ដូចជាអនុសញ្ញាស្ដីពីសិទ្ធិជនមានពិការភាព (CRPD) យុទ្ធសាស្ត្រអ៊ីនឈុន (INCHEON) ដើម្បី "ធ្វើឱ្យពិតប្រាកដត្រឹមត្រូវ" សម្រាប់ជនមានពិការភាពនៅតំបន់ អាស៊ី និងប៉ាស៊ីហ្វិក ដោយស្របទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។

ការអភិវឌ្ឍន៍នៃគោលការណ៍ណែនាំនេះ គឺអាចធ្វើទៅបាន ដោយមានការគាំទ្រថវិការបស់ទីភ្នាក់ងារអភិវឌ្ឍន៍សាធារណរដ្ឋឆែក (CzDA) ដែលជាផ្នែកនៃគម្រោងរយៈពេល ៣ ឆ្នាំ "ដំណើរឆ្ពោះទៅរកបរិយាបន្នការងារសម្រាប់ជនមានពិការភាព" (ដែលត្រូវបានចាប់ផ្តើមតាំងពីខែវិច្ឆិកា ឆ្នាំ២០២១ និងបញ្ចប់នៅខែធ្នូ ឆ្នាំ២០២៣) ហើយគម្រោងនេះផងដែរ ត្រូវបានសហការអនុវត្តដោយ អង្គការភីប ផលអ៊ីននីត (People In Need Cambodia) និងសាខាក្រុមហ៊ុនអ៊ែជ្យាយល៍ ឌីវេឡុមម៉ិន គ្រុប ភីធីវ៉ាយ អិលធីឌី (Agile Development Group) ក្នុងគោលបំណងស្វែងរកការកែលម្អលទ្ធភាព ទទួលបានឱកាសការងារសមរម្យសម្រាប់ជនមានពិការភាព។ ជាលទ្ធផលនៃគម្រោង ជនមានពិការភាពនឹងទទួលបាន ជំនាញដែលត្រូវទៅនឹងតម្រូវការរបស់ស្ថាប័នឯកជន ក៏ដូចជាគាំទ្រជនមានពិការភាព ក្នុងការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេ និងបង្កើនការអនុវត្តទៅលើបរិយាបន្ន សម្រាប់ស្ថាប័នអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ និងក្រុមនិយោជក។

យើងសង្ឃឹមថាគោលការណ៍ណែនាំនេះ នឹងអាចជាឧបករណ៍ដ៏មានប្រយោជន៍មួយសម្រាប់ស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងអ្នកពាក់ព័ន្ធក្នុងការជំរុញប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយបរិយាបន្ន ការគោរព និងការផ្តល់តម្លៃលើភាពចម្រុះ ជាពិសេសគឺធានាឱ្យបាននូវឱកាសស្មើៗគ្នាសម្រាប់ជនមានពិការភាព។

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADG | សាខាក្រុមហ៊ុន អ៊ែដ្យាយល៍ ឌីវេឡុមម៉ិន គ្រុប ភីធីវ៉ាយ អិលធីឌី |
| PwDs | ជនមានពិការភាព |
| TVET | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| MOLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOSVY | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| RECU | R = ការទៅដល់ (Reach), E = ការចូលក្នុង (Enter), C = ការផ្លាស់ទី (Circulation), U = ការប្រើប្រាស់ (Usage) |
| PTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត |
| VTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ |

# ជំពូកទី១៖ ការស្វែងយល់អំពីពិការភាព

## ១.១ គោលបំណង

មុនពេលចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចឱ្យបានបរិយាបន្ន វាចាំបាច់ណាស់ក្នុងការមានការយល់ដឹងជា មូលដ្ឋានអំពីពិការភាព។ ផ្នែកនេះនឹងណែនាំអំពីគោលគំនិត និងនិយមន័យសំខាន់ៗនៃពិការភាព និង ផ្នត់គំនិតនៃពិការភាព ដែលបង្ហាញពីរបៀបដែលយើងត្រូវយល់ដឹង អំពីការកំណត់ឧបសគ្គដែលជនមានពិការភាពជួបប្រទះនៅក្នុងសង្គម។ ជំពូកនេះមានគោលបំណង ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការរៀនសូត្របន្ថែម និងការគិតប្រកបដោយការស្តាបនាអំពីបញ្ហាទាក់ទងនឹងពិការភាព។

### ១.២ តើអ្វីទៅជាពិការភាព?

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ (UNCRPD)** ទទួលស្គាល់ ពិការភាពជាទស្សនទានដែលមានការវិវត្ត ហើយចែងថា៖

> “**ជនមានពិការភាព** សំដៅលើអ្នកទាំងឡាយ ដែលមានភាពអន់ខ្សោយរយៈពេលយូរ ផ្នែកកាយសម្បទា ផ្លូវចិត្ត ប្រាជ្ញា ឬ វិញ្ញាណដែលនៅពេលជួបប្រទះ ឧបសគ្គនានាអាចរារាំងពួកគេមិនឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពក្នុងសង្គមដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ”។

**ពិការភាព = កម្សោយ + ឧបសគ្គ**

## ១.៣ ផ្នត់គំនិតនៃពិការភាព

ផ្នត់គំនិតនៃ «ពិការភាព» កំពុងតែមានការផ្លាស់ប្តូរ ហើយយើងត្រូវបន្តធ្វើការងារនេះតទៅមុខទៀត។ តាមការគិតបែបប្រពៃណី ក្រុមជនដែលមានពិការភាពត្រូវបានកំណត់លក្ខណៈដោយអ្វីដែលពួកគេមិនអាចធ្វើបាន។ ការគិតបែបនេះនាំឱ្យពួកគេទទួលរងនូវភាពព្រងើយកន្តើយ ហើយលើសពីនោះ ត្រូវបានអ្នកដទៃរើសអើងដោយសកម្មផងដែរ។ ទស្សនទានបែបនេះ ត្រូវបានគេហៅថាគំរូបែប "ប្រពៃណី" ឬ "សប្បុរសធម៌" និង "គំរូបែបវេជ្ជសាស្ត្រ" នៃពិការភាព។

ប៉ុន្តែវិធីសាស្ត្រដែលល្អប្រសើរ ក្នុងការកំណត់អត្តសញ្ញាណពិការភាពគឺជាការធ្វើអន្តរកម្មរបស់បុគ្គលជាមួយនឹងសង្គមរបស់ពួកគេ។ គំរូនេះជាការផ្លាស់ប្តូរការផ្តោតលើបញ្ហាបុគ្គល ហើយដាក់បន្ទុកនោះទៅលើសង្គមវិញ ដែលត្រូវបានគេហៅថា "គំរូសង្គម" នៃពិការភាព។ គំរូសង្គមនេះហើយ ដែលជាវិធីសាស្ត្រដ៏ល្អ ដើម្បីឱ្យមនុស្សគ្រប់រូបចូលរួមគាំទ្រដល់ពិការភាព។

- **គំរូសប្បុរសធម៌**

ការយល់ថាបុគ្គលដែលមិនអាចដើរ ឬមើលឃើញ ពួកគេត្រូវការជំនួយផ្នែកសប្បុរសធម៌ដូចជា ការអាណិតអាសូរ ការពឹងពាក់ និងការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ។

គំរូទាំងនេះអាចធ្វើឱ្យសង្គមមិនអើពើនឹងទំនួលខុសត្រូវ ដោយពួកគេគិតថាមានអ្នកផ្សេងទៀតនឹងចូលមកដោះស្រាយក្នុងលក្ខណៈជាសប្បុរសធម៌ ហើយពួកគេមិនចាំបាច់ធ្វើអ្វីក្រៅពីនេះទៀតទេ។ ការយល់ឃើញនោះគឺជនមានពិការភាពជាប្រភពនៃបញ្ហា មិនមែនមកពីសង្គមមិនបានរាប់បញ្ចូលបុគ្គលនោះទេ តែដោយសារបុគ្គលនោះមិនមានសមត្ថភាពក្នុងការឱ្យគេដាក់បញ្ចូលខ្លួនទៅក្នុងសង្គម។

ទាំងនេះហើយដែលនាំឱ្យជនដែលមានពិការភាពគិតថាខ្លួនគាត់មានអ្វីមួយដែលមិនប្រក្រតី។ សាកស្រមៃថា អ្នកតែងតែត្រូវបានគេប្រាប់ថា អ្នកគឺជាបញ្ហាដែលតែងតែត្រូវការដំណោះស្រាយ។ ហើយមិនមែនត្រឹមតែមនុស្សម្នាក់ប៉ុណ្ណោះទេ ដែលមកប្រាប់អ្នកថាអ្នកជាបញ្ហា ប៉ុន្តែ

សង្គមទាំងមូលផងដែរ។ បន្ទាប់ពីឮហើយ តើអ្នកមានទំនុកចិត្តដែរឬទេ? តើអ្នកមានផាសុកភាពនៅក្នុងសហគមន៍ឬសង្គមរបស់អ្នកដែរឬទេ?

- **គំរូបែបវេជ្ជសាស្ត្រនៃពិការភាព**

ទស្សនៈនៃការមើលឃើញនៃគំរូនេះ យល់ឃើញថា ពិការភាពជារឿងរបស់បុគ្គលម្នាក់ៗ ដែលមានបញ្ហាសុខភាពដែលត្រូវការការព្យាបាល ឬទប់ស្កាត់។ ប្រសិនបើពិការភាព របស់ពួកគេមិនអាចលុបបំបាត់ បានទេ នោះបុគ្គលទាំងនេះក្លាយជា “បញ្ហាសប្បុរសធម៌”។ ពួកគេត្រូវបាន ចាត់ថ្នាក់ថា ជាមនុស្ស “អកុសល” ដែលត្រូវការការអាណិតអាសូរ និងការ ទទួលបានសេវាសប្បុរសធម៌។




គំរូបែបវេជ្ជសាស្ត្រ ផ្តោតសំខាន់លើអ្វីដែលជនមានពិការភាពមិនអាចធ្វើបានដោយសារតែកម្សោយរបស់ពួកគេ។ ដូច្នេះដើម្បីដោះស្រាយនូវកម្សោយរបស់ពួកគេ យើងត្រូវការ ការផ្តល់ជាសម្ភារៈ ឬឧបករណ៍ (រទេះរុញ ជើង ឬដៃសិប្បនិមិត្ត វ៉ែនតា ឈើវាស ឈើច្រត់) និងការមើលថែផ្សេងៗ។

**ឧទាហរណ៍៖** នាងមិនអាចដើរបានទេ ដូច្នេះនាងត្រូវការរទេះរុញ។

- នាងមិនអាចមើលឃើញបានទេ ដូច្នេះនាងត្រូវការជំនួយការ។
- នាងមិនអាចស្តាប់បានទេ ដូច្នេះនាងត្រូវការឧបករណ៍ជំនួយការស្តាប់។

- **គំរូបែបសង្គមនៃពិការភាព**




ចាប់កំណើតនៅទសវត្សឆ្នាំ ១៩៦០ គំរូសង្គមនៃពិការភាព មានភាពខុសគ្នាខ្លាំង ដែលចែងថាពិការភាពគឺជាលទ្ធផល របស់មនុស្ស ដែលមានបញ្ហាចុះខ្សោយក្នុងការធ្វើអន្តរកម្ម នៅក្នុងបរិស្ថាន និងបរិបទសង្គម។ ពិការភាពមិនមែន ជាការចុះខ្សោយដែលមានផលវិបាក មិនអាចចៀសផុត បាននោះទេ ប៉ុន្តែវាបណ្តាលមកពីរបៀបដែលសង្គម ដំណើរការនិងរៀបចំ។ ភាពចុះខ្សោយអាចយល់បាន តាមលក្ខណៈរូបរាងកាយរបស់មនុស្ស។ ឧទាហរណ៍៖

- មនុស្សម្នាក់មានការពិបាកក្នុងការដើរ។
- មនុស្សម្នាក់មានការពិបាកក្នុងការមើល។

ឧបសគ្គមួយកើតឡើងគឺ នៅពេលដែលសង្គមមិនអាចផ្តល់នូវវិធានការគ្រប់គ្រាន់ដើម្បីដាក់បញ្ចូលមនុស្សម្នាក់ដែលមានកម្សោយ។ នៅពេលមនុស្សម្នាក់ដែលពិបាកក្នុងការដើរត្រូវប្រឈមនឹងជណ្តើរ ពួកគេត្រូវស្ថិតក្នុងស្ថានភាពមានពិការភាព។ នៅពេលមនុស្សម្នាក់ដែលពិបាកក្នុងការមើលត្រូវប្រឈមមុខនឹងអត្ថបទដែលមានតួរអក្សរតូចៗពណ៌ស្រាលពួកគេស្ថិតក្នុងស្ថានភាពមានពិការភាព។

- មនុស្សម្នាក់ដែលពិបាកក្នុងការដើរ ផ្តល់ឱ្យពួកគេនូវជម្រាលផ្លូវឡើងមួយ។
- មនុស្សម្នាក់ដែលមានការពិបាកក្នុងការមើលផ្តល់ឱ្យពួកគេនូវឯកសារដែលងាយស្រួលអាន ( អត្ថបទមានតួរអក្សរធំៗ ពុម្ពអក្សរសាមញ្ញនិងពណ៌ដិត)។

យោងតាមបរិបទខាងលើ សង្គមគឺជាប្រភពនៃពិការភាពហើយវាងាយស្រួលណាស់ក្នុងការសង្កេតមើល

- គ្មានជម្រាលផ្លូវឡើង = រទេះរុញមិនអាចឡើងបាន = មិនមានលទ្ធភាពចូលក្នុងអាគារ **= ការមិនដាក់បញ្ចូលជនដែលមានពិការភាព**
- ពិបាកក្នុងការអានឯកសារ = មិនបានអានឯកសារ = គ្មានចំណេះដឹង **= ការមិនដាក់បញ្ចូលជនដែលមានពិការភាព**

## ១.៤ ប្រភេទសំខាន់ៗនៃពិការភាព

ការកំណត់និយមន័យ **"ពិការភាព"** គឺមានលក្ខណៈស្មុគស្មាញ ប៉ុន្តែវិធីសាស្រ្តក្នុងការយល់អំពីពិការភាពនោះ គឺការបែងចែកប្រភេទពិការភាពជា ៥ ប្រភេទ។[1]

| សម្គាល់៖ មនុស្សអាចមានកម្រៃយច្រើនយ៉ាងក្នុងពេលតែមួយ។ |
|---|

### ១.៤.១ ពិការភាពកាយសម្បទា

ពិការភាពកាយសម្បទានេះ រាប់បញ្ចូលទាំងកម្រៃយមុខងារសរីរាង្គ ចលករនិង/ឬការបំលាស់ទី។ ទាំងនេះអាចមានការបម្រែបម្រួលឬភាពមិនប្រក្រតីនៃប្រព័ន្ធភាពសាំ មានភាពរីកលូតលាស់ ឬមិនលូតលាស់ ពេលខ្លះអាចមើលឃើញឬក៏មើលមិនឃើញជួនកាលមានភាពឈឺចាប់ខ្លាំង ឈឺចាប់តិចតួច និងមិនមានការឈឺចាប់ទាល់តែសោះក៏មាន។

**កម្រៃយមានភាពលូតលាស់ (Progressive)** ៖ កម្រៃយទាំងនេះកាន់តែយ៉ាប់យ៉ឺនទៅៗទៅតាមពេលវេលា ប៉ុន្តែវាអាចប្រែប្រួលបានតាមភាពជាក់ស្តែង៖

- ជម្ងឺក្រិន (Multiple Sclerosis) បណ្តាលមកពីកង្វះជីវជាតិនៃប្រព័ន្ធសរសៃប្រសាទ។
- ជម្ងឺសាច់ដុំ (Muscular Dystrophy) បណ្តាលមកពីបញ្ហាសាច់ដុំ សាច់ដុំមិនដំណើរការ។
- ជម្ងឺរលាកសន្លាក់រ៉ាំរ៉ៃ (Chronic Arthritis)។

**កម្រៃយមិនមានភាពលូតលាស់ (Non-Progressive)៖** កម្រៃយទាំងនេះនឹងមិនមានការលូតលាស់នោះទេ ហើយមានស្ថេរភាព។

- ការប៉ះពាល់ចលករខួរក្បាល (Cerebral Palsy)៖ សំដៅលើការអភិវឌ្ឍខួរក្បាលរួមទាំងពិការភាពហៀរន ភាពខុសប្រក្រតីនៃខួរក្បាលដែលបណ្តាលឱ្យពិការខួរក្បាល។
- ការប៉ះពាល់ខួរឆ្អឹងខ្នង (Spina Bifida)៖ អាចបណ្តាលមកពីការខូចទ្រង់ទ្រាយពីកំណើតនៃខួរឆ្អឹងខ្នង ឬក៏ប៉ះពាល់ដល់ស្រោមខួរ ដែលកត្តាទាំងនេះអាចបណ្តាលឱ្យមានពិការភាព ដល់អវយវៈក្រោម។

[1] យោងតាមគោលការណ៍ណែនាំអំពីការកំណត់អត្តសញ្ញាណពិការភាពតាមគំរូសង្គមនិងសិទ្ធិជាមូលដ្ឋានរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខែសីហា ២០២០

- របួសខួរឆ្អឹងខ្នង (Spinal Cord Injury)៖ សំដៅលើការខូចខាតសរសៃប្រសាទដែលបណ្តាលមកពីការរងរបួសឆ្អឹងខ្នង ការខូចខាតដល់ឆ្អឹងខ្នង សរសៃចង ឬថាសនៃជួរឈរឆ្អឹងខ្នង ឬការប៉ះពាល់នៃផ្នែកណាក្នុងចំណោមនេះ។

ប៉ុន្តែកម្សោយខាងក្រោមនេះគឺមិនមានការលូតលាស់ទេ តែអាចមានការប្រែប្រួល៖

- ស្ថានភាពឈឺចាប់រ៉ាំរ៉ៃ (Fibromyalgia)៖ បណ្តាលឱ្យមានការឈឺចាប់សាច់ដុំ សរសៃពួរ និងសន្លាក់។ វាក៏ត្រូវបានកំណត់លក្ខណៈដោយការគេងមិនលក់ អស់កម្លាំង ការថប់អារម្មណ៍ ការបាក់ទឹកចិត្ត និងការរំខានដល់មុខងារពោះវៀនផងដែរ។
- ជម្ងឺអស់កម្លាំងរ៉ាំរ៉ៃ (Chronic fatigue syndrome)៖ បង្កឡើងដោយភាពអស់កម្លាំងខ្លាំងដែលមានរយៈពេលយ៉ាងហោចណាស់ ប្រាំមួយខែ ហើយដែលមិនអាចពន្យល់បានពេញលេញយោងទៅតាមស្ថានភាពសុខភាព។

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ពិបាកធ្វើចលនាលើ** | សំដៅទៅលើ ការចុះខ្សោយតាមរយៈការខូចខាត ឬការបាត់បង់ជា អចិន្ត្រៃយ៍នៃផ្នែកអវយវៈលើ (ដៃ) រួមទាំងភាពរួមស្វិត ភាពកន្ត្រាក់នៃសាច់ដុំឬមិនកម្រើកបានដោយ សារប្រព័ន្ធសរសៃប្រសាទពាក់ព័ន្ធនឹងដៃ។ | ដាច់ដៃ (ផ្នែកនៃប្រអប់ដៃ ឧទាហរណ៍៖ ម្រាមដៃ សន្លាក់ដៃ ក្រោមកំភួនដៃ សន្លាក់កែងដៃ លើកែងដៃ សន្លាក់ស្មា និងហួសសន្លាក់ស្មា) ស្វិតសាច់ដុំដៃ គាំងសន្លាក់ដៃ បាក់ឆ្អឹងដៃធ្ងន់ធ្ងរ សាច់ដុំដៃរួញខ្លី ខូចចលករខួរក្បាល ដៃខ្វេរ ដៃកែក ទន់ដៃ ខូចស្មា និងខូចទ្រង់ទ្រាយដៃ។ |
| **ពិបាកធ្វើចលនាក្រោម** | សំដៅទៅលើការចុះខ្សោយ ការខូចខាត ឬការបាត់បង់ជា | ដាច់ជើង (ប្រអប់ជើង សន្លាក់កជើង ក្រោមជង្គង់ |

| | | |
|---|---|---|
| | អចិន្ត្រៃយ៍នៃអវយវៈក្រោម(ជើង) រួមទាំងភាពរួមស្វិត ភាពកន្ត្រាក់នៃសាច់ដុំ ឬប្រព័ន្ធសរសៃប្រសាទពាក់ព័ន្ធនឹងជើង។ | សន្លាក់ជង្គង់ លើជង្គង់ សន្លាក់ត្រគាក...) ស្វិតសាច់ដុំជើង គាំងសន្លាក់ជើង បាក់ឆ្អឹងធ្ងន់ធ្ងរ សាច់ដុំរួញខ្លី ខ្វិចចលករខួរក្បាល ជើងខ្វេរ ជើងកែក ទន់ជើង ភ្លាត់ត្រគៀកធ្ងន់ធ្ងរ ស្លាប់មួយចំហៀងខ្លួន ឬមួយកំណាត់ខ្លួន ខូចសសៃធ្ងន់ធ្ងរ គ្រិចធ្ងន់ធ្ងរ រលាកធ្ងន់ធ្ងរ។ |
| **ពិបាកសម្របសម្រួលដងខ្លួន ខ្នងនិងសរីរាង្គផ្សេងៗនៃរាងកាយ** | សំដៅលើការខូចទ្រង់ទ្រាយនៃដងខ្លួន ឬខ្នងនិងសរីរាង្គផ្សេងៗនៃរាងកាយ ដែលធ្វើឱ្យចុះខ្សោយ ឬបាត់បង់មុខងារនៃសរីរាង្គនោះជាអចិន្ត្រៃយ៍។ | ខូចទ្រង់ទ្រាយឆ្អឹងខ្នង (កោងទៅមុខ កោងទៅក្រោយ ឬកោងទៅចំហៀង) ឆ្អឹងកងក (កោង ឬវៀច) ពិការដោយសារ ផលវិបាកនៃជម្ងឺរបួសខួរឆ្អឹងខ្នង ជម្ងឺលើសសម្ពាធឈាម និងជម្ងឺស្ត្រូប...។ |
| **ពិការភាពសរីរាង្គខាងក្នុង** | សំដៅលើ ការរះកាត់នៃសរីរាង្គខាងក្នុងសំខាន់ៗ ដែលបានចុះខ្សោយ ខូចខាតសរីរាង្គខាងក្នុង ឬ ការចុះខ្សោយមុខងារនៃភាពស៊ាំនិងមានជម្ងឺរ៉ាំរ៉ៃ ជាអចិន្ត្រៃយ៍ (ពិការភាពនេះត្រូវមាន ការបញ្ជាក់ពីគ្រូពេទ្យជំនាញ)។ | មានប្រវត្តិវះកាត់ធំ ឬកំពុងមានជម្ងឺរ៉ាំរ៉ៃឬខ្សោយខូចខាតទាំងស្រុងនៃ មុខងារសរីរាង្គខាងក្នុង (ឧទាហរណ៍៖ បេះដូង ក្រលៀន លំពែង ប្រព័ន្ធដង្ហើម តម្រងនោម ពោះវៀន ថ្លើម ក្រពះ |

| | | |
|---|---|---|
| | | ឬសរីរាង្គផ្សេងទៀត។ |

### ១.៤.២ ពិការភាពញាណដឹង

- **កម្រោយគំហើញ ឬពិបាកក្នុងការមើល៖** សំដៅដល់ "ការពិបាកក្នុងការមើល"។ "ពិការភាពភ្នែក" ច្រើនតែត្រូវបានគេពិពណ៌នាអំពីមនុស្សម្នាក់ដែលមានសមត្ថភាពមើលឃើញត្រឹម ១០% ឬតិចជាងនេះ វាមិនបង្ហាញថាបុគ្គលនោះ ពិការភាពភ្នែកទាំងស្រុងនោះទេ។ ហើយមានតែ ១០% នៃជនមានពិការភាពភ្នែកសរុបតែប៉ុណ្ណោះ ដែល មានពិការភាពភ្នែកទាំងស្រុង ហើយ ៩០% ទៀតត្រូវបានគេពិពណ៌នាថាជាការចុះខ្សោយនៃការមើលឃើញ។

- **កម្រោយការស្តាប់៖** សំដៅលើការពិបាកក្នុងការស្តាប់។ **"គម្លង់"** ពិពណ៌នាអំពីបុគ្គលដែលមានការពិបាកក្នុងការស្តាប់ធ្ងន់ធ្ងរឬមិនអាចស្តាប់ឮទាល់តែសោះ។ អ្នកអាចទទួលរងការបាត់បង់ការស្តាប់នៅពេលឈានចូលវ័យជំទង់ ឬវ័យចំណាស់វាត្រូវ បានគេហៅជា ញឹកញាប់ថា "ថ្លង់" ។

| ប្រភេទកម្រោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ពិបាកក្នុងការស្តាប់** | សំដៅលើ ការពិបាកឬលទ្ធភាព នៃការស្តាប់ចុះខ្សោយ ខូចខាត ឬបាត់បង់ការស្តាប់ទាំងស្រុង។ | ថ្លង់ ត្រចៀកអត់រន្ធពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរដំបៅអំបែកធ្ងន់ធ្ងររន្ធត្រចៀកមានដុំពក។ |
| **ពិបាកក្នុងការនិយាយ** | សំដៅលើការពិបាកក្នុងការបញ្ចេញសំឡេង និយាយមិនច្បាស់ ឬនិយាយមិនរួចទាល់តែសោះឬអ្នកដទៃពិបាកស្តាប់។ | ការនិយាយត្រឡាន់ (អណ្តាតធំ) និយាយត្រដិតធ្ងន់ធ្ងរ ឆែបក្រអូមមាត់ ក្រឡេតមិនល្អ ក្ងរ និយាយមិនច្បាស់ និយាយមិនចេញ ឬគ។ល។ |
| **ពិបាកក្នុងការមើល** | សំដៅលើ ការចុះខ្សោយ | ងងឹតភ្នែកម្ខាង ឬទាំងសងខាង |

| | | |
|---|---|---|
| | ខូចខាត ឬមិនអាចមើលឃើញ (ពីកំណើតដោយសារគ្រោះថ្នាក់ ឬរបួស ឬជម្ងឺ ឬវ័យជរា...។ល។) | ស្វិតសរសៃបាតភ្នែក ភ្នែកលៃនមើលមិនឃើញ កន្ទុយថ្លែនធ្ងន់ធ្ងរ បណ្តាលឱ្យមានប្រែងចាក់ ភ្នែកស្រលៀង ភ្នែកម្ញូប ធ្លាក់ត្របកភ្នែក សម្លាកកញ្ចក់ភ្នែក សម្ពាធទឹកក្នុងភ្នែកកើនឡើង រលាកសរសៃបាតភ្នែក ងងឹតពណ៌។ |

### ១.៤.៣ ពិការភាពសតិបញ្ញា

វាជាជម្ងឺជាក់លាក់ និងជាប់លាប់មួយនៃប្រព័ន្ធសរសៃប្រសាទកណ្តាលរបស់មនុស្សដែលប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការរៀនសូត្រដូចមនុស្សទូទៅ។ នេះអាចប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការយល់ពីអ្វីដែលពួកគេបានឃើញនិងឮ ឬភ្ជាប់ ព័ត៌មានរវាងផ្នែកផ្សេងៗនៃខួរក្បាល។ មួយក្នុងចំណោមសូចនាករទូទៅនៃការចុះខ្សោយការរៀនសូត្រ គឺភាពខុសគ្នារវាងសក្តានុពលរបស់បុគ្គលម្នាក់ៗ (សមត្ថភាពជាក់ស្តែង និងបញ្ញា) និងកម្រិតនៃសមិទ្ធិផលសម្រេចបានរបស់ពួកគេ។

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ដោនស៊ីនដ្រូម** | សំដៅលើ វិបល្លាសហ្សែនជនមានបញ្ហានេះតែងមានភិនភាគលក្ខណៈមុខមាត់ សម្គាល់ពិសេស មានបញ្ហាលូតលាស់យឺតយ៉ាវ បញ្ហាក្នុងការមើលការស្តាប់និងសុខភាពផ្សេងៗទៀត។ | មិនចងចាំ ពិបាកខ្លាំងក្នុងការរៀនសូត្រ មិនសូវយល់ដឹង។ មិនស្តាប់បង្គាប់ ឆាប់ខឹងមួម៉ៅ បោកក្បាលពេលខឹង ការនិយាយស្តីមិនច្បាស់ មិនអាចចាត់ចែងសកម្មភាព រស់នៅប្រចាំថ្ងៃដោយខ្លួនឯងបាន។ |
| **អូទីស្សឹម** | សំដៅលើបញ្ហាខួរក្បាល | មិនដឹងពីអារម្មណ៍ឬការឆ្លើយ |

| | | |
|---|---|---|
| | ដែលអភិវឌ្ឍមូលដ្ឋានខួរក្បាលយឺតដោយមិនដឹងមូលហេតុ ឬវិធីព្យាបាលឱ្យជាសះស្បើយ។ អូទីស្សឹមអាចមានកម្រិតស្រាល មធ្យម និងធ្ងន់។ | តបរបស់អ្នកដទៃ។ ពិបាកនិយាយពីអារម្មណ៍របស់ខ្លួន ឬក្នុងការឆ្លើយតបទៅអ្នកស្ដាប់វិញ។ សកម្មភាពដដែលៗ និងពិបាកក្នុងការទទួលយក ឬពិបាកក្នុងការសម្របខ្លួន ជាមួយបរិបទជុំវិញខ្លួន។ |
| **ពិការចលករខួរក្បាល** | សំដៅលើ សរសៃប្រសាទមិនរីកចម្រើនដែលជះឥទ្ធិពលដល់ចលនា រាងកាយនិងការសម្របសម្រួល សាច់ដុំបណ្ដាលមកពីការខូចខាតផ្នែកជាក់លាក់មួយ ឬច្រើននៃខួរក្បាល ហើយជាទូទៅកើតឡើងមុនពេល អំឡុងពេលឬភ្លាមៗបន្ទាប់ពីកំណើត។ | ដៃជើងរឹង ការធ្វើចលនាមិនប្រក្រតី ញ័រ ឬចលនាដោយអចេតនា មិនអាចធ្វើចលនាបានស្ពឹកស្រពន់ ឬ សាច់ដុំរឹងការហៀរទឹកមាត់ និងមានភាពលូតលាស់យឺតខុសធម្មតា រួមទាំងការនិយាយ និងអាកប្បកិរិយា។ |

### ១.៤.៤ ពិការភាពផ្លូវចិត្ត

វាមានសារៈសំខាន់ណាស់ក្នុងការដឹងថារាល់បញ្ហាសុខភាពផ្លូវចិត្តទាំងអស់ មិនមែនសុទ្ធតែជាកម្សោយនោះទេ។ វាត្រូវបានចាត់ទុកថាជាពិការភាពផ្លូវចិត្ត លុះត្រាតែវាមានផលប៉ះពាល់ដែលមានរយៈពេលវែងក្នុងសកម្មភាពប្រចាំថ្ងៃ។ ស្ថានភាពសុខភាពផ្លូវចិត្តមានច្រើនប្រភេទខ្លះអាចមើលឃើញ ខ្លះមិនអាចមើលឃើញនោះទេ។ ទោះជាយ៉ាងណាក៏ដោយអ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្ត ឬប៉ះពាល់ផ្លូវចិត្ត ភាគច្រើនត្រូវទទួលបានការរើសអើង។

- ជម្ងឺវិកលចរិក៖ ជារឿយៗត្រូវបានគេចាត់ទុកថាជាស្ថានភាពសុខភាពផ្លូវចិត្ត ធ្ងន់ធ្ងរបំផុត។

- ជម្ងឺផ្លូវចិត្ត រួមមានការបាក់ទឹកចិត្ត ថប់បារម្ភ ជម្ងឺបាយប៉ូឡា (bipolar disorder)។
- ជម្ងឺភ្លេចភ្លាំង (Dementia)៖ ភាគច្រើនកើតមានចំពោះមនុស្សវ័យចំណាស់ ប៉ុន្តែជម្ងឺភ្លេចភ្លាំងនៅដំណាក់កាលដំបូងក៏អាចកើតមានចំពោះមនុស្សវ័យក្មេងផងដែរ។
- ជម្ងឺស្ត្រេស (Post Traumatic Stress Disorder)៖ ការប៉ាន់ប្រមាណបាន ឱ្យដឹងថា ២៨.៤% នៃប្រជាជនកម្ពុជាទទួលរងពីជម្ងឺស្ត្រេស សញ្ញាណទូទៅទាក់ទងនឹងជម្ងឺស្ត្រេសនេះគឺពិបាកក្នុងការផ្តោតអារម្មណ៍ ឬចងចាំ។
- ភាពមិនប្រក្រតីនៃរបបអាហារ (Eating Disorders including Anorexia and Bulimia)៖ ទាក់ទងនឹងការតមអាហារ ការញ៉ាំមិនទៀងទាត់ ញ៉ាំលើសកម្រិត វាក៏ជាផ្នែកមួយពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្តដែរ។
- ជម្ងឺភ័យខ្លាច (Obsessive-Compulsive disorders)៖ វាកើតនៅពេលដែលនរណាម្នាក់ទទួលរងនូវការបង្ខិតបង្ខំ ឬអ្វីដែលពួកគេមិនចង់បាន។

| ប្រភេទកម្សោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ពិការភាពផ្លូវចិត្ត** | សំដៅលើវិបត្តិផ្នែក អាកប្បកិរិយា អារម្មណ៍ និងការគិតដែលកើតឡើង ជាប្រចាំ ហើយរំខានដល់ការ បំពេញមុខងារប្រចាំថ្ងៃ។ | ជំងឺមន្ទិលសង្ស័យ វិកលចរិកខូចសតិអារម្មណ៍ តានតឹងផ្លូវចិត្ត ជំងឺបាក់ទឹកចិត្ត ថប់អារម្មណ៍ ជំងឺវង្វេង អាក្រាតនិយាយ សើច យំ ច្រៀងរាំលេងតែម្នាក់ឯងខុស ប្រក្រតីស្ងឹងស្ងាធ ជេរគេ ជេរឯង វាយឬប្រព្រឹត្តអំពើ ហិង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់។ យំរាំតែម្នាក់ឯង ជួនកាលក៏ស្ងាត់ មិននិយាយស្តី ចូលចិត្តដាក់ទោសឬធ្វើបាបលើខ្លួនឯងដោយមិនខ្វល់ ពីគ្រោះថ្នាក់។ |

| | | |
|---|---|---|
| **ពិបាកក្នុងការចងចាំ** | សំដៅលើសមត្ថភាពយល់ដឹង ការវែកញែក ការសម្រេចចិត្ត ដោយប្រើប្រាស់ភាសា ការនិយាយ ការស្តាប់ និងការអានអក្ខរាវិរុទ្ធ ឬការគិតលេខនពន្ធ ដែលបណ្តាលមក ពីការចុះខ្សោយសមត្ថភាពរ៉ាំរ៉ៃ។ ឬមុខងារខួរក្បាល ការអភិវឌ្ឍខួរក្បាល និងជំងឺវង្វេងវង្វាន់។ | ភាពចាស់ជរា របួសខួរក្បាល តំណពូជ ការរួមតូចនៃសរសៃឈាម ដែលផ្គត់ផ្គង់លំហូរឈាមទៅខួរក្បាលជំងឺសរសៃឈាមបេះដូង ដុំសាច់ក្នុងខួរក្បាល កង្វះអាហារូបត្ថម្ភ និងជំងឺវង្វេងវង្វាន់ បណ្តាលមកពីជំងឺឆ្លងរ៉ាំរ៉ៃ។ |

### ១.៤.៥ ពិការភាពផ្សេងៗ

| ប្រភេទកម្រោយ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **ជំងឺរមួលសារពាង្គកាយមិនប្រក្រតី** | សំដៅលើជំងឺប្រព័ន្ធប្រសាទខួរក្បាលរ៉ាំរ៉ៃដែលបង្កឱ្យមានការរំខាន ដល់ដំណើរការធម្មតារបស់កោសិកាខួរក្បាល ដែលប៉ះពាល់ដល់សតិស្មារតី ចលនារាងកាយក្នុងរយៈពេលខ្លី។ | ប្រកាច់ ឬកន្ត្រាក់សាច់ដុំបែកពពុះមាត់ ភ្នែកស្លឹឡើងលើ ខាំអណ្តាតហើយសន្លប់បាត់ស្មារតីមួយសន្ទុះក្រោយមកក៏ដឹងខ្លួនឡើងវិញហើយភ្លេចរឿងដែលកើតមានឡើង |
| **ពិការភាពផ្សេងៗ** | សំដៅលើ ការពិបាកបំពេញមុខងារនៃរាងកាយ សង្គម ឬមានពិការភាពដែល មិនអាចចាត់ចូលជាប្រភេទពិការភាពណា មួយខាងលើ ឬមានពិការភាពច្រើនប្រភេទទៀត | មុខមាត់ខូចទ្រង់ទ្រាយ ក្បាលធំ តឿ ក្រិន ពកក ផលវិបាកក្នុងការបំពេញមុខងារដោយសារគ្រោះថ្នាក់ (រលាកទឹកអាស៊ីត ទឹកក្តៅ ឬរលាកភ្លើង)។ |

### ពិការភាព “កំបាំង”

ពិការភាពលាក់កំបាំង ឬមើលមិនឃើញ គឺជាស្ថានភាពផ្លូវកាយ ផ្លូវចិត្ត ឬសរសៃប្រសាទ ដែលមិនអាចមើលឃើញពីខាងក្រៅ ប៉ុន្តែអាចកំណត់ ឬប្រឈមនឹងចលនា អារម្មណ៍ ឬសកម្មភាពរបស់មនុស្ស។ ឧទាហរណ៍រួមមាន ការឈឺចាប់ខ្លាំង អស់កម្លាំង វិលមុខ ខូចមុខងារនៃការយល់ដឹង របួសខួរក្បាល ការលំបាកក្នុងការសិក្សា និងបញ្ហាសុខភាពផ្លូវចិត្ត ហើយក៏អាចសំដៅទៅលើការចុះខ្សោយនៃការស្តាប់ និងការមើលផងដែរ។

វាជារឿងសំខាន់ដែលត្រូវយល់ថាការចុះខ្សោយទាំងនេះ មិនតែងតែច្បាស់សម្រាប់អ្នកមើលនោះទេ ប៉ុន្តែជួនកាល ឬតែងតែអាចកំណត់សកម្មភាពប្រចាំថ្ងៃ និងមានចាប់ពីបញ្ហាប្រឈមកម្រិតស្រាលរហូតដល់កម្រិតធ្ងន់ធ្ងរ និងប្រែប្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។

## ២. ឧបសគ្គចំពោះបរិយាបន្នពិការភាព

វិធីល្អបំផុតមួយដើម្បីស្វែងយល់ពីគំរូសង្គមនៃពិការភាព និងវិធីដើម្បីយកឈ្នះការមិនដាក់បញ្ចូលជនដែលមានពិការភាពគឺនៅលើ“**ការរារាំងឧបសគ្គ**”។ មានទិដ្ឋភាពនៃសង្គមជាច្រើនដែលធ្វើឱ្យជីវិតមានការលំបាកសម្រាប់បុគ្គលដែលមានកម្សោយ ហើយមិនដាក់បញ្ចូលពួកគេក្នុងការចូលរួមក្នុងសង្គមពេញលេញ។ រនាំងឧបសគ្គសំខាន់ៗរួមមាន៖

**ឧបសគ្គបែបអាកប្បកិរិយា៖** មានឥរិយាបថសង្គម និងវប្បធម៌ និងការសន្មតជាច្រើនទាក់ទងនឹងមនុស្សមានកម្សោយរួមមាន ការវិនិច្ឆ័យមិនត្រឹមត្រូវ ការប្រកាន់ពូជសាសន៍ ការរើសអើង និងការមិនដាក់បញ្ចូលទៅក្នុងសង្គម។ ឧទាហរណ៍ ការសន្មតថាបុគ្គលដែលមានពិការភាពមិនអាចធ្វើការបាន មិនមានឯករាជ្យភាព មិនអាចរួមភេទ មិនគួរមានកូន ត្រូវការការគាំពារដូចជាកូនក្មេង ងាយប្រឈមនឹងគ្រោះថ្នាក់ និងជនមានពិការភាពមិនគួរឱ្យឃើញ ព្រោះធ្វើឱ្យអ្នកដទៃមានអារម្មណ៍មិនល្អ។

**ឧបសគ្គបែបបរិស្ថាន ឬ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** ទាំងនេះជារនាំងដែលត្រូវបានផ្សាភ្ជាប់ទៅនឹងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានជុំវិញ គ្របដណ្តប់លើឧបសគ្គធំៗដែលរារាំងការចូលរួមដែលមានភាពស្មើគ្នា មានដូចជា៖ កាំជណ្តើរ ច្រកទ្វារចេញចូលតូចចង្អៀត តុខុសស្តង់ដារ គ្មានជម្រាលផ្លូវ បង្គន់អនាម័យមិនបង្កលក្ខណៈងាយស្រួល

លំនៅដ្ឋានដែលមិនមានភាពងាយស្រួល កន្លែងអង្គុយមិនមានភាពល្អប្រសើរ មិនមានពន្លឺគ្រប់គ្រាន់ ជណ្តើរយន្តខូច កំរាលថ្មផ្លូវក្រាលមិនស្មើគ្នាទាំងក្នុងនិងនៅលើផ្លូវសាធារណៈ។

**ឧបសគ្គបែបព័ត៌មានឬការទំនាក់ទំនង៖** ឧបសគ្គទាំងនេះត្រូវបានផ្សាភ្ជាប់ទៅនឹងកង្វះភាសាសញ្ញា ឬអ្នកបកប្រែសម្រាប់មនុស្សដែលមានបញ្ហាខ្សោយសោតវិញ្ញាណ (ការស្តាប់)។ កង្វះនូវការផ្តល់ពត៌មានក្នុងទម្រង់ផ្សេងៗគ្នាដូចជា សំភារៈបោះពុម្ពដែលបង្កលក្ខណៈងាយស្រួល (ពុម្ពអក្សរធំ ការរចនាក្រហ្វិកសាមញ្ញ)។

**ឧបសគ្គបែបស្ថាប័ន៖** ឧបសគ្គទាំងនេះពាក់ព័ន្ធនឹងការរើសអើង ក៏ដូចជាច្បាប់ការងារ ប្រព័ន្ធបោះឆ្នោត និងគោលនយោបាយសិក្សាអប់រំនៅមានកម្រិត។

- មនុស្សមួយចំនួនមានកម្សោយជាក់លាក់ ប៉ុន្តែជារឿយៗបរិយាកាសជុំវិញ និងអាកប្បកិរិយារបស់សង្គមទេដែលបានរារាំងពួកគេមិនឱ្យចូលរួមបាន។
- វាជារឿងសំខាន់ដែលត្រូវដឹងថាពិការភាពមិនមែនជា បុគ្គលិកលក្ខណៈនោះទេ វាជាលទ្ធផលនៃការឆ្លើយតប (អន្តរកម្ម) របស់បុគ្គល និងបរិយាកាសរបស់គាត់។
- ស្ថានភាពដែលរារាំង គឺនៅពេលដែលមនុស្សម្នាក់មិនមានកាយសម្បទាគ្រប់គ្រាន់ និងមិនមានឱកាសដូចអ្នកដទៃ។

# ជំពូកទី២៖ ពិការភាព និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) ក្នុងបរិបទកម្ពុជា។

## ទិដ្ឋភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជាបច្ចុប្បន្ន

យោងតាមរបាយការណ៍ជីវៈប្រវត្តិនៃប្រទេសដែលមានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈពីអង្គការយូណេស្កូ។ ប្រតិបត្តិការនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅកម្ពុជាមានចំនួន ២ប្រភេទ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈបែបផ្លូវការ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈបែបក្រៅប្រព័ន្ធ ហើយប្រភេទនីមួយៗនេះ គឺវាមានការកំណត់ ប្រជាសាស្រ្តខុសៗគ្នានៃសិស្ស ដោយផ្អែកលើបទពិសោធន៍សិក្សារបស់ពួកគេ (យូណេស្កូ ឆ្នាំ២០២០)។

1. TVET Systems

TVET in Cambodia's education system




[13] Compiled by UNESCO-UNEVOC International Centre. For a detailed overview and exact mobility between various programmes, please see page 6

## ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈបែបផ្លូវការ

ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈបែបផ្លូវការ ត្រូវបានបែងចែកជា ៣ កម្មវិធីផ្សេងៗគ្នាបន្តទៀត៖ កម្មវិធីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ កម្មវិធីសញ្ញាប័ត្រវិជ្ជាជីវៈ និងកម្មវិធីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅក្នុងកម្រិតឧត្តមសិក្សា។

1) សម្រាប់ **កម្មវិធីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ៖** បន្ទាប់ពីបានបញ្ចប់ការអប់រំ អនុវិទ្យាល័យ សិស្សមានជម្រើសក្នុងការបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ឬក៏អាចចុះឈ្មោះចូលរៀនក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈតែម្តង។ ដោយពួកគេត្រូវបញ្ចប់ការសិក្សាវិញ្ញាបនប័ត្រ ចំនួន ៣ វគ្គជាមុនសិន ឬក៏ពួកគេអាចចុះធ្វើកម្មសិក្សាបន្ទាប់ពីទទួលបានវិញ្ញាបនបត្របញ្ចប់ការសិក្សាក្នុងមួយវគ្គៗ។ ជាជម្រើសបន្ថែម ពួកគេអាចបញ្ចប់ការសិក្សាកម្រិតទី ១ នៃវគ្គបណ្តុះបណ្តាលស្ពានចម្លងជាមុនសិន ដើម្បីអាចទទួលបានសិទ្ធិចូលសិក្សាកម្មវិធីថ្នាក់បរិញ្ញាបត្រ។ ហើយវគ្គសិក្សាកម្មវិធីថ្នាក់បរិញ្ញាបត្រនេះមានមុខជំនាញដូចជា ការ

ជួសជុលយានយន្ត បច្ចេកវិទ្យាកុំព្យូទ័រ និងវិស្វកម្មសំណង់ស៊ីវិល (យូណេស្កូ ឆ្នាំ២០២០ ទំព័រ០៦)។

2) ម្យ៉ាងវិញទៀតចំពោះ **កម្មវិធីសញ្ញាប័ត្រវិជ្ជាជីវៈ** មានមុខជំនាញនៅក្នុងផ្នែកបច្ចេកទេស និងផ្នែកសហគ្រិនភាព។ ហើយបន្ទាប់ពីទទួលបានសញ្ញាបត្រ និស្សិតមានជម្រើសសិក្សាកម្មវិធីបរិញ្ញាបត្រវិជ្ជាជីវៈបន្តបាន ដោយចុះឈ្មោះក្នុងវគ្គបណ្តុះបណ្តាលស្ពានចម្លង ដើម្បីទទួលបានសិទ្ធិចូលសិក្សាក្នុងកម្មវិធីថ្នាក់បរិញ្ញាបត្រវិជ្ជាជីវៈដែលផ្តោតលើបច្ចេកវិទ្យា ក៏ដូចជាទទួលបានឱកាសចុះធ្វើកម្មសិក្សា (យូណេស្កូ ឆ្នាំ២០២០ ទំព័រ០៦)។

3) សម្រាប់ **កម្មវិធីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅក្នុងកម្រិតឧត្តមសិក្សា៖** ពហុបច្ចេកទេសផ្តល់វគ្គសិក្សាកម្រិតឧត្តមសិក្សាក្នុងផ្នែកដូចជា វិស្វកម្ម និងវិទ្យាសាស្ត្រសុខាភិបាល។ កម្មវិធីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មាននៅកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងក្រោយឧត្តមសិក្សា។ ដើម្បីចុះឈ្មោះថ្នាក់បរិញ្ញាបត្រក្នុងកម្មវិធីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និស្សិតត្រូវមានសញ្ញាប័ត្រវិជ្ជាជីវៈ ឬត្រូវបញ្ចប់ការអប់រំទូទៅមធ្យមសិក្សាទុតិយភូមិ និងឆ្លងកាត់កម្មវិធីសិក្សាស្ពានចម្លងជាមុនសិន។ ហើយសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ (អនុបណ្ឌិត) និងបណ្ឌិតតម្រូវឱ្យនិស្សិតបញ្ចប់ត្រឹម កម្រិតបរិញ្ញាបត្រជាមុនសិន (យូណេស្កូ ឆ្នាំ២០២០ ទំព័រ០៦)។

## ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបែបក្រៅប្រព័ន្ធ

ការត្រួតពិនិត្យលើគោលនយោបាយនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ របស់អង្គការយូណេស្កូ (ឆ្នាំ ២០១៣) បានថែងថា មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត (PTC) និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (VTC) គឺជាប្រភពចម្បងនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈបែបក្រៅប្រព័ន្ធ។ លើសពីនេះទៅទៀត ក៏មានស្ថាប័នសាធារណៈ និងអ្នកផ្តល់សេវាឯកជនផ្សេងទៀតផ្តល់កម្មសិក្សាក្រៅផ្លូវការផងដែរ។ វគ្គសិក្សាទាំងនោះគឺមានរយៈពេលខ្លី និងផ្តោតលើផ្នែកជាច្រើនដូចជា កសិកម្ម សំណង់ ការជួសជុលម៉ូតូ និងការកែច្នៃចំណីអាហារជាដើម។ សម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលខេត្ត នៅមិនទាន់មានកម្មវិធីស្តង់ដារណាមួយនៅឡើយទេ ជាពិសេសគឺប្រតិបត្តិការនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលនោះផងដែរ។ រាជរដ្ឋាភិបាល និងម្ចាស់ជំនួយក៏បានបង្កើតជាកញ្ចប់នៃមូលនិធិបណ្តុះបណ្តាលសម្រាប់កម្មវិធីអភិវឌ្ឍជំនាញក្រៅប្រព័ន្ធនេះផងដែរ។ ចាប់ពីឆ្នាំ ២០០៩ ដល់

ឆ្នាំ ២០១៩ ដែលមានមនុស្សចំនួន ១១៩,១៩២ នាក់ (ស្រី ៥៦,៨៨២ នាក់) បានទទួលអត្ថប្រយោជន៍ពីមូលនិធិបណ្តុះបណ្តាលទាំងនេះ (យូណេស្កូ ឆ្នាំ២០២០ ទំព័រ០៧)។ នាពេលបច្ចុប្បន្នកម្មវិធីនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបែបក្រៅប្រព័ន្ធមួយចំនួន ដំណើរការទៅបានដោយមានការឧបត្ថម្ភពី មូលនិធិបណ្តុះបណ្តាលជាតិ កម្មវិធីបណ្តុះបណ្តាលជំនាញប័ណ្ណ (VSTP) មូលនិធិ ពិសេសរបស់នាយករដ្ឋមន្ត្រី មូលនិធិពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងកម្មវិធីបច្ចេកវិទ្យាក្រោយការប្រមូលផល និងកម្មវិធីស្តានចម្លងជំនាញនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (យូណេស្កូ ឆ្នាំ២០១៣ ទំព័រ៣១).

## សមិទ្ធិផលបរិយាបន្នរបស់រដ្ឋាភិបាលសម្រាប់ជនមានពិការភាព

យោងតាមផែនការយុទ្ធសាស្ត្រឆ្នាំ ២០១៩-២០២៣ ស្តីពីការអភិវឌ្ឍន៍នៃវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ការបណ្តុះ-បណ្តាលវិជ្ជាជីវៈ និងជំនាញសហគ្រិនភាពត្រូវបានផ្តល់ជូនជនមានពិការភាពក្នុងវិស័យ ផ្សេងៗគ្នា ចំនួន ១,០៨១ នាក់ ជាមួយនឹង ៣៨៥ នាក់ ដែលទទួលបានការងារ។ លើសពីនេះទៀត អង្គការដៃគូបានចុះឈ្មោះកុមារដែលមានពិការភាពចំនួន ១,០២៨ នាក់ នៅក្នុងវគ្គសិក្សាសម្រាប់ ភាសាសញ្ញា និងប្រតិចារិក (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ ២០១៨ ទំព័រ ០៨)។

## បញ្ហាប្រឈម

ជនមានពិការភាព ក៏ដូចជាជនមានភាពក្រីក្រ ជួបប្រទះការរើសអើងក្នុងសង្គម បញ្ហាផ្លូវកាយ និងហិរញ្ញវត្ថុ ដែលកំណត់លទ្ធភាពទទួលបានការថែទាំសុខភាព ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។ ទាំងអស់នេះហើយ ដែលរារាំងសមត្ថភាពរបស់ពួកគេក្នុងការចូលរួម និងទទួលបានអត្ថប្រយោជន៍ពី សេដ្ឋកិច្ច (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១៨ ទំព័រ០៩)។

យោងតាមរបាយការណ៍ជីវៈប្រវត្តិនៃប្រទេសដែលមានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ៖ បោះពុម្ពដោយអង្គការយូណេស្កូ បានបញ្ជាក់ថាគុណភាពនៃអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈនៅប្រទេសកម្ពុជា មិនទាន់ឆ្លើយតបនឹងតម្រូវការទីផ្សារការងារនៅឡើយទេ ដោយសារកត្តាជាច្រើនរួមមានកង្វះប្រព័ន្ធធានាគុណភាព វិធីសាស្ត្របណ្តុះបណ្តាលហួសសម័យ គ្រូបណ្តុះបណ្តាលមានបទពិសោធន៍តិចក្នុងវិស័យឧស្សាហកម្ម ហេដ្ឋារចនាសម្ព័ន្ធនិងឧបករណ៍បណ្តុះបណ្តាលនៅមាន

កម្រិត ជាពិសេសគឺកង្វះនៃបទប្បញ្ញត្តិពាក់ព័ន្ធ ក៏ដូចជាប្រព័ន្ធវាយតម្លៃដែលទទួលស្គាល់ដោយឧស្សាហកម្មសម្រាប់គ្រូបណ្តុះបណ្តាល និងសិក្ខាកាម (យូណេស្កូ ឆ្នាំ២០២០ ទំព័រ១៤)។ តំណភ្ជាប់ និងការតម្រង់ទិសផ្លូវនៃការអប់រំទូទៅ និងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅមានកម្រិត។ ជាងនេះទៅទៀត ការអនុវត្តកម្មវិធីបណ្តុះបណ្តាលស្តានចម្លងជំនាញ និងវិញ្ញាបនបត្រនៅទូទាំងក្រសួងនានា ក៏ដូចជាអ្នកផ្តល់វគ្គបណ្តុះបណ្តាលដែលមិនមែនជាសាធារណៈ គឺនៅមិនទាន់មានភាពទូលំទូលាយនៅឡើយ (យូណេស្កូ ឆ្នាំ២០២០ ទំព័រ១៤)។ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវបានគេមើលឃើញជាញឹកញាប់ក្នុងទស្សនៈអវិជ្ជមាន ថាជាជម្រើសនៃការអប់រំ ដែលមានតម្លៃទាបសម្រាប់តែបុគ្គលដែលមានភាពក្រីក្រ។ ការយល់ឃើញនេះបង្ហាញពីបញ្ហាប្រឈមចំពោះការចុះឈ្មោះក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការអភិវឌ្ឍន៍វិស័យការងារសម្រាប់ឧស្សាហកម្មបច្ចុប្បន្ន និងនាពេលខាងមុខ (យូណេស្កូ ឆ្នាំ២០២០ ទំព័រ១៤)។

## បរិយាបន្ននៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ជនមានពិការភាព

យោងតាមរបាយការណ៍ត្រួតពិនិត្យគោលនយោបាយរបស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា បានបង្ហាញថាការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រ។ វាទទួលបានភាពជោគជ័យគួរឱ្យកត់សម្គាល់ និងតម្រូវឱ្យមានការបង្កើន ក៏ដូចជាកែលម្អទាំងទំហំ និងគុណភាពជាបន្តទៀត។ កត្តាទាំងនេះ នឹងនាំទៅដល់ការសម្រេចឱ្យបាននូវការអភិវឌ្ឍន៍គុណវុឌ្ឍិ នៃធនធានមនុស្ស ការបង្កើតឱកាសការងារ ការទាក់ទាញនៃការវិនិយោគ និងការដោះស្រាយបញ្ហានានា ដូចជាចរន្តនៃពលកម្ម និងការបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ានក្រោយឆ្នាំ ២០១៥ (យូណេស្កូ ឆ្នាំ២០១៣ ទំព័រ៣៤) ដូច្នេះហើយ ចាំបាច់ត្រូវធ្វើឱ្យមានបរិយាបន្ននៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ជនមានពិការភាព។ ក្នុងន័យនេះផងដែរ រដ្ឋាភិបាលបាននឹងកំពុងធ្វើការ និងគិតគូរអំពីវិធីសាស្ត្រក្នុងការដាក់បញ្ចូលជនមានពិការភាពនៅក្នុងយុទ្ធសាស្ត្រ និងសកម្មភាពថ្នាក់ជាតិ ដើម្បីធានាថាពួកគេមានភាពឯករាជ្យទាំងផ្នែកសង្គម និងសេដ្ឋកិច្ច។

នៅក្នុងចំនុច ៣.២.២ នៃការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ពីរបាយការណ៍របស់អង្គការយូណេស្កូ ស្តីពីការត្រួតពិនិត្យគោលនយោបាយនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា ដោយមានទិសដៅយុទ្ធសាស្ត្រមួយដែល

បានលើកឡើង “ពង្រឹងការបណ្តុះបណ្តាលដោយផ្អែកលើគោលការណ៍សមធម៌ ដោយផ្តល់អាទិភាពដល់ស្ត្រី ជនដែលមានភាពក្រីក្រ ឬជនដែលមានពិការភាព យុវជនដែលមានភាពក្រីក្រ និងអ្នកដែលបោះបង់ការសិក្សា” (យូណេស្កូ ឆ្នាំ២០១៣ ទំព័រ៣៤)។ ជាងនេះទៅទៀត នៅក្នុងរបាយការណ៍ដដែលនោះ ឆ្នាំ ២០១១ ក៏មានសារាចរណែនាំស្តីពីគុណភាពនៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបន្ថែមទៀត ក្នុងគោលបំណងលើកកម្ពស់យុត្តិធម៌ក្នុងវិស័យអប់រំ ដោយផ្តល់អាទិភាពដល់ស្ត្រី ជនមានពិការភាព យុវជនដែលមានភាពក្រីក្រ និងអ្នកដែលបោះបង់ការសិក្សា។ គំនិតផ្តួចផ្តើមដោយចាប់ផ្តើមមានគម្រោងអាហារូបករណ៍ និងការបង្កើតអន្តេវាសិកដ្ឋាន នឹងត្រូវបានផ្តល់ជូនចំពោះក្រុមគោលដៅ (យូណេស្កូ ឆ្នាំ២០១៣ ទំព័រ៤៦)។

ទោះយ៉ាងណាក៏ដោយ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយបរិយាបន្នសម្រាប់ជនមានពិការភាព នៅតែមានចន្លោះខ្វះខាតនៅឡើយ។ ភស្តុតាងនៅក្នុងសៀវភៅព័ត៌មានអំពីស្ថាប័ននៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាំងសាធារណៈ និងឯកជន ដែលបានបោះពុម្ពដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងខែមីនា ឆ្នាំ២០២២ ដោយក្នុងនោះបានបញ្ជាក់ថា មានត្រឹមតែ ៤ ស្ថាប័ន (ដែលមានទីតាំងនៅក្រៅរាជធានីភ្នំពេញ) ក្នុងចំណោម ៣៨ ស្ថាប័នតែប៉ុណ្ណោះ ដែលបានបង្ហាញពីការលើកទឹកចិត្តដល់ជនងាយរងគ្រោះ និងជនមានពិការភាព នៅក្នុងសេចក្តីថ្លែងការណ៍បេសកកម្ម និងសកម្មភាពរបស់ពួកគេ។

នៅក្នុងផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុកម្មវិធី ១.៣៖ *ការអភិវឌ្ឍសុខុមាលភាពរបស់ជនមានពិការភាព* ដែលមានគោលបំណងលើកកម្ពស់សិទ្ធិជនមានពិការភាព និងលុបបំបាត់ការរើសអើងប្រឆាំងនឹងពួកគេ ដែលក្នុងនោះរួមមានការអភិវឌ្ឍភាសាសញ្ញា ការផ្តល់សិទ្ធិអំណាចតាមរយៈការស្តារនីតិសម្បទា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការគាំទ្រទៅលើអាជីវកម្មខ្នាតតូច ក៏ដូចជាការលើកកម្ពស់ការចូលរួមក្នុងកីឡា និងសិល្បៈ ដើម្បីបង្កើនកម្រិតជីវភាព និងសេចក្តីថ្លៃថ្នូររបស់ពួកគេ។ សកម្មភាពទាំងនោះ រួមមាន ការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យពិការភាព ការអនុវត្តកម្មវិធីផ្ទេរប្រាក់សម្រាប់ជនមានពិការភាពក្នុងសហគមន៍ ការផ្តល់ជាវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងឱកាសការងារ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងសហគ្រាសឯកជន ដើម្បីផ្តល់ការងារដល់ជនមានពិការភាព និងកែលម្អជាសុកវត្ថុលើកកម្ពស់ការប្រើប្រាស់ឧបករណ៍ជំនួយ និងភាសាសញ្ញា ជាពិសេសមានជាកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីអភិវឌ្ឍ និងបណ្តុះបណ្តាលអក្សរស្ទាប និងភាសាសញ្ញា (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១៨ ទំព័រ៣០)។

# ជំពូកទី៣៖ ការរួមបញ្ចូលជនមានពិការភាព នៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ៖ មគ្គុទេសន៍ឆ្ពោះទៅកាន់ បរិយាបន្នពិការភាព

ខាងក្រោមនេះគឺជាមគ្គុទេសន៍ណែនាំតាមបរិបទសាមញ្ញសម្រាប់បុគ្គលិករដ្ឋបាល គ្រូបង្រៀន និងក្រុមអ្នកដឹកនាំនៅក្នុងស្ថាប័នអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET)។ មគ្គុទេសន៍ណែនាំនេះគឺដើម្បីជួយដល់ស្ថាប័នបណ្តុះបណ្តាលនីមួយៗក្នុងការធ្វើផែនការ និងដំណើរការធ្វើការសម្រេចចិត្តរបស់ពួកគេក្នុងការធ្វើឱ្យមជ្ឈមណ្ឌលរបស់ពួកគេទទួលបានបរិយាបន្នសម្រាប់ទាំងអស់គ្នា។
ការអនុវត្តគោលការណ៍ណែនាំនេះនឹងនាំឱ្យមានការលើកកម្ពស់បរិយាបន្នក្នុងវិស័យបណ្តុះបណ្តាលជំនាញនិងវិជ្ជាជីវៈនៅកម្ពុជា។ ការអនុវត្តគោលការណ៍ណែនាំមួយចំនួននឹងទាមទារឱ្យមានការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MOLVT) និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការឬស្ថាប័នដែលធ្វើការលើវិស័យពិការភាព និង អ្នកផ្តល់សេវា។

គោលការណ៍ណែនាំនេះត្រូវបានបែងចែកទៅជាផ្នែកដែលរួមមានសកម្មភាពមួយចំនួនដែលគួរអនុវត្តដែលបង្ហាញពីសារៈសំខាន់ និងឥទ្ធិពលរបស់វាទៅលើដំណើរការបណ្តុះបណ្តាលរបស់សិស្សមានពិការភាព។

## តើដូចម្តេចទៅទើបហៅថា បរិយាបន្ន ឬ ការរួមបញ្ចូល?

បរិយាបន្នក្នុងបរិបទអប់រំ មានន័យថាអ្នកមាននិងគ្មានពិការភាពរៀននៅក្នុងថ្នាក់ជាមួយគ្នា។ មជ្ឈមណ្ឌលបណ្តុះបណ្តាល ឬស្ថាប័នជំនាញវិជ្ជាជីវៈមានទំនួលខុសត្រូវទាំងផ្លូវច្បាប់ និងផ្លូវសីលធម៌ ក្នុងការលុបបំបាត់នូវឧបសគ្គទាំងឡាយ ដោយធ្វើឱ្យមជ្ឈមណ្ឌលបណ្តុះបណ្តាលមានលក្ខណៈងាយស្រួល និងគាំទ្រពិការភាពគ្រប់ប្រភេទដើម្បីឱ្យជនមានពិការភាពអាចចូលរួមបានពេញលេញ និងរៀនជាមួយមិត្តភក្តិដែលគ្មានពិការភាពរបស់ពួកគេ។

### ស្ថាប័នដែលមានបរិយាបន្នគឺៈ

- បង្កលក្ខណៈងាយស្រួលដល់មនុស្សគ្រប់រូប ដោយគ្មានការរើសអើង រួមទាំងអគារ ព័ត៌មាន ការទំនាក់ទំនង កម្មវិធីសិក្សា សម្ភារៈអប់រំ បច្ចេកវិទ្យា វិធីសាស្ត្របង្រៀន

ការវាយតម្លៃ ភាសា និងសេវាកម្មគាំទ្រផ្សេងៗ។ ការរចនាជាសកលត្រូវបានណែនាំដោយធានាថាបរិយាកាស (ទាំងនៅក្រៅ និងក្នុងអនឡាញ) និងឧបករណ៍សម្រាប់ការបង្រៀន និងការសិក្សា ត្រូវបានរចនាឡើងដើម្បីជំរុញឱ្យមាននូវបរិយាបន្ន និងធានាសមភាពក្នុងដំណើរការអប់រំ និងសកម្មភាពក្នុងថ្នាក់។ ការសម្របសម្រួលសមរម្យត្រូវបានផ្ដល់ជូនដល់សិស្សមានពិការភាពដើម្បីបំពេញតម្រូវការជាក់លាក់របស់ពួកគេ។

➢ **អាចសម្របសម្រួលបាន** ដូចជាកម្មវិធីសិក្សាត្រូវបានរៀបចំឡើងនិងអនុវត្តដើម្បីបំពេញនិងកែតម្រូវតាមតម្រូវការរបស់សិស្សគ្រប់រូប។ ការវាយតម្លៃលក្ខណៈស្តង់ដារត្រូវបានជំនួសដោយការវាយតម្លៃដែលមានភាពបត់បែន និងមានច្រើនទម្រង់ធ្វើឡើងសម្រាប់ការទទួលស្គាល់នូវវឌ្ឍនភាពរបស់បុគ្គលដែលឆ្ពោះទៅរកគោលដៅធំដែលផ្តល់នូវជម្រើសច្រើនក្នុងការសិក្សា។

នៅក្នុងជំពូកនេះ យើងនឹងស្វែងយល់ពីវិធីសាស្ត្រដែលអាចអនុវត្តបាន សម្រាប់មជ្ឈមណ្ឌលអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈដើម្បីបង្កើតបរិយាបន្នសម្រាប់សិស្សមានពិការភាព។

# ៣.១. ការធ្វើផែនការបរិយាបន្ន

ការធ្វើផែនការបរិយាបន្នគឺជាវិធីសាស្រ្តជារួមដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណងរបស់ស្ថាប័ននោះ ហើយវាក៏អាចជួយបង្កើនភាគរយនៃភាពជោគជ័យ។

### ៣.១.១ ការបង្កើតនូវការប្តេជ្ញាចិត្តសម្រាប់បរិយាបន្នពិការភាព

យុទ្ធសាស្រ្តក្នុងការកសាងការប្តេជ្ញាចិត្តសម្រាប់ការបង្កើតឱ្យមានបរិយាបន្នសម្រាប់សិស្សមានពិការភាពនៅក្នុងវិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកម្មវិធីបណ្ដុះបណ្ដាលរបស់ខ្លួនរួមមាន៖

### ៣.១.១ ក. បង្កើតឱ្យមាននូវសេចក្តីថ្លែងការណ៍នៃចក្ខុវិស័យ និងបេសកកម្មសម្រាប់បរិយាបន្ន



សេចក្តីថ្លែងការណ៍នៃ**ចក្ខុវិស័យ**និង**បេសកកម្ម**សម្រាប់បរិយាបន្នអាចជួយផ្សព្វផ្សាយនូវគោលដៅក៏ដូចជាគោលបំណងនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទៅកាន់ស្ថាប័នពាក់ព័ន្ធរួមមាន បុគ្គលិក សិស្ស អាណាព្យាបាល និយោជក និងដៃគូផ្សេងៗ។ វាក៏អាចជួយ
ណែនាំនៃការធ្វើផែនការការអនុវត្តគោលនយោបាយប្រកបដោយបរិយាបន្នផងដែរ។ សេចក្តីថ្លែងការណ៍ចក្ខុវិស័យ និងបេសកកម្មគួរតែបង្កើតឡើងតាមរយៈដំណើរការចូលរួមពីសំណាក់អ្នកដែលពាក់ព័ន្ធនឹងការទទួលយកមតិត្រឡប់របស់ជនមានពិការភាព និងអ្នកតំណាងរបស់ពួកគេ ក៏ដូចជាក្រុមពាក់ព័ន្ធផ្សេងទៀតផងដែរ។ សេចក្តីថ្លែងការណ៍គួរតែត្រូវបានពិនិត្យ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីធានាបាននូវភាពពាក់ព័ន្ធ និងប្រសិទ្ធភាពរបស់វា។

ការធ្វើការប្តេជ្ញាចិត្តក្នុង "ការធ្វើការដើម្បីសម្រេចបាននូវបរិយាបន្ន" អាចដាក់បង្ហាញនៅលើគេហទំព័រផ្លូវការរបស់ស្ថាប័ន ក៏ដូចជាតាមរយៈឯកសារផ្សព្វផ្សាយផ្សេងៗ។

**ឧទាហរណ៍នៃចក្ខុវិស័យរួមនិងបេសកកម្មសម្រាប់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ចក្ខុវិស័យរបស់យើងគឺ**ដើម្បីក្លាយជាមជ្ឈមណ្ឌលវិជ្ជាជីវៈដែលឈានមុខគេក្នុងការផ្តល់ការបណ្តុះបណ្តាលជំនាញរួមនិងគុណភាពសម្រាប់អ្នកសិក្សាទាំងអស់ជាពិសេសអ្នកដែលប្រឈមមុខនឹងឧបសគ្គក្នុងការអប់រំនិងការងារដោយសារពិការភាព ការធ្វើចំណាកស្រុក

យេនឌ័រ ឬកត្តាផ្សេងៗទៀត។

**បេសកកម្មរបស់យើងគឺ**ផ្តល់សិទ្ធិអំណាចដល់អ្នកសិក្សារបស់យើងជាមួយនឹងជំនាញពាក់ព័ន្ធនឹងទីផ្សារដែលអាចឱ្យពួកគេទទួលបានការងារសមរម្យនិងឱកាសក្លាយជាសហគ្រិននិងដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចក្នុងសហគមន៍របស់ពួកគេ។

**យើងប្តេជ្ញា**ក្នុងការលើកកម្ពស់សមធមិភាពចម្រុះនិងបរិយាបន្នទៅក្នុងកម្មវិធីTVETនិងការអនុវត្តរបស់យើង និងដើម្បីសហការជាមួយដៃគូនិងអ្នកពាក់ព័ន្ធរបស់យើងដើម្បីបង្កើតប្រព័ន្ធ TVETដែលប្រកបដោយបរិយាបន្ន។



### ៣.១.១.២ បង្កើតផែនទីបង្ហាញផ្លូវឆ្ពោះទៅរកបរិយាបន្នពិការភាព

**កំណត់គោលបំណង៖**

លើអ្វីដែលស្ថាប័នចង់សម្រេចឱ្យបាននិងគួរតែស្របជាមួយបេសកកម្មនិងគុណតម្លៃនៃស្ថាប័នផងដែរ។ អង្គភាពគ្រប់គ្រងនៃស្ថាប័ននោះអាចជាអ្នកធ្វើសកម្មភាពនេះ ដោយមានជំនួយពីអ្នកជំនាញ/ទីប្រឹក្សាពិការភាពពីខាងក្រៅស្ថាប័ន (ព័ត៌មានបន្ថែម និងទំនាក់ទំនងនៅក្នុង ឧបសម្ព័ន្ធទី ១ ) តាមរយៈការបង្កើតដំណាក់កាលជាក់លាក់នៃសកម្មភាព។

**កំណត់តួនាទីនិងទំនួលខុសត្រូវ៖**

បុគ្គលនៅក្នុងស្ថាប័នដែលមានភារៈកិច្ចទទួលខុសត្រូវចំពោះគោលដៅ ឬចំពោះដំណាក់កាលជាក់លាក់នៃសកម្មភាពបរិយាបន្នផ្សេងៗចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់។

បុគ្គលិកដែលមានតួនាទីលើបរិយាបន្នពិការភាពត្រូវតែកំណត់ឱ្យបានច្បាស់លាស់ដើម្បីជម្រុញការងារបរិយាបន្នឱ្យទៅមុខ តាមរយៈការបង្កើតឱ្យមានក្រុមការងារបច្ចេកទេសប្រចាំស្ថាប័នផ្ទាល់ក្នុងការត្រួតពិនិត្យមើលផែនការសកម្មភាព តម្រង់ទិសការបង្កើតគោល

នយោបាយ ធ្វើផែនការថវិកា និងការអនុវត្តវិធានការបរិយាបន្នពិការភាព។ ប្រសិនបើអាចសមាជិកនៃក្រុមការងារបច្ចេកទេស នោះគួរតែជាតំណាងមកពីដេប៉ាតឺម៉ង់ផ្សេងៗ។

**កំណត់នូវរយៈពេលមួយៈ**

កំណត់នូវកាលបរិច្ឆេទចាប់ផ្តើមនិងកាលបរិច្ឆេទបញ្ចប់។ត្រូវកំណត់សកម្មភាពរយៈពេលខ្លីមធ្យមនិងវែងរួមជាមួយនឹងសូចនាករជាក់លាក់ច្បាស់លាស់និងអាចធ្វើទៅបានដើម្បីតាមដាននិងធ្វើការវាយតម្លៃនូវវឌ្ឍនភាពនិងឥទ្ធពល។

**ប៉ាន់ប្រមាណការចំណាយៈ**

កំណត់ចំណាយដែលចាំបាច់ក្នុងការសម្រេចបាននូវគោលបំណង មានដូចជាធនធានដែលត្រូវការសម្រាប់ធ្វើការបណ្តុះបណ្តាលបុគ្គលិក ការកែប្រែសម្ភារៈបរិក្ខារ ឬកម្មវិធីសិក្សា ការផ្តល់ឧបករណ៍ជំនួយ និងសេវាកម្មគាំទ្រ និងការលើកកម្ពស់ការយល់ដឹងក្នុងទៅកាន់ភាគីពាក់ព័ន្ធ។ ក្នុងករណីខ្វះខាតធនធាន (មនុស្ស និងហិរញ្ញវត្ថុ) គោលបំណងនៃបរិយាបន្នអាចនឹងត្រូវកែសម្រួល ឬបន្ថែមសកម្មភាពមួយចំនួនក្នុងការរៃអង្គាសមូលនិធិ។

### ៣.១.១.គ បង្កើតឱ្យមាននូវគោលការណ៍គ្មានការរើសអើង

គោលនយោបាយទាំងនេះគួរតែធានាថាជនមានពិការភាពទទួលបាននូវភាពស្មើគ្នាក្នុងការទទួលបានសេវាកម្មនិងកម្មវិធីនៃវគ្គបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនិងប្រាកដថាពួកគេនឹងមិនត្រូវបានការរើសអើងគ្រប់រូបភាពនិងការបៀតបៀនដោយសារពិការភាពរបស់ពួកគេ។ គោលការណ៍របស់ស្ថាប័នគួរតែរួមបញ្ចូលការផ្តល់ឱ្យនូវការសម្របសម្រួលសមរម្យ និងការគាំទ្រផ្សេងៗសម្រាប់ជនមានពិការភាពក្នុងការចូលរួមពេញលេញក្នុងសកម្មភាពនៃវគ្គបណ្តុះបណ្តាលនិងសម្រេចបាននូវលទ្ធផលសិក្សារបស់ពួកគេ។ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃគោលនយោបាយរបស់ស្ថាប័ន លទ្ធផលនៃការធ្វើខុសពីគោលការណ៍គួរតែកំណត់ឱ្យបាន

ច្បាស់ និងឱ្យបុគ្គលគ្រប់រូបនៅក្នុងស្ថាប័នដឹងលឺតាំងពីដំបូង ហើយការដាក់ពិន័យលើការបំពានលើគោលការណ៍គ្មានការរើសអើងនេះគួរតែដាក់អនុវត្តជាកំហិត។

**ឧទាហរណ៍នៃគោលនយោបាយគ្មានការរើសអើងសម្រាប់ ស្ថាប័ន TVET**

[ស្ថាប័ន]
ប្តេជ្ញាផ្តល់នូវបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពនិងរួមបរិយាបន្ននិងគ្មានការរើសអើងលើពូជសាសន៍ពណ៌សម្បុរ សញ្ជាតិដើម ភេទ អត្តសញ្ញាណយេនឌ័រ ទំនោរផ្លូវភេទ
ពិការភាព អាយុ សាសនា ឬលក្ខណៈផ្សេងៗទៀតដែលត្រូវបានការពារនៅ លើកម្មវិធី
សកម្មភាព ការចូលរៀន ឬការអនុវត្តការងាររបស់យើង។
យើងគោរពនិងឱ្យតម្លៃលើភាពចម្រុះនៃសហគមន៍របស់យើង ហើយ
យើងនឹងខិតខំលើកកម្ពស់វប្បធម៌នៃការគោរព និងសមធម៌ សម្រាប់ គ្រប់គ្នា។

សិស្សបុគ្គលិកមាតាបិតាឬអាណាព្យាបាលណាដែលជឿថាពួកគេឬនរណាម្នាក់ផ្សេងទៀតត្រូវបានរើសអើង ឬការបៀតបៀនដោយ ផ្អែកលើលក្ខខណ្ឌដែលត្រូវបានការពារ
គួរតែរាយការណ៍ពីឧប្បត្តិហេតុនេះទៅកាន់អ្នកសម្របសម្រួលលើគោលការណ៍គ្មានការរើសអើងឬមន្ត្រីសាលាផ្សេងទៀតឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

[ស្ថាប័ន]
នឹងធ្វើការស៊ើបអង្កេតភ្លាមៗនូវរាល់របាយការណ៍នៃការរើសអើងឬការបៀតបៀនហើយចាត់វិធានការសមស្របដើម្បីបញ្ឈប់ទប់ស្កាត់និងដោះស្រាយរាល់ការបំពានលើគោលការណ៍នេះ។យើងក៏នឹងរក្សាការសម្ងាត់និងឯកជនភាពរបស់ភាគីទាំងអស់ដែលពាក់ព័ន្ធក្នុងដំណើរការបណ្តឹងតាមលទ្ធភាពដែលអាចធ្វើទៅបាន។

*[ស្ថាប័ន]* ហាមឃាត់រាល់ការវាយប្រហារចំពោះបុគ្គលដែលរាយការណ៍ ឬចូលរួមក្នុងការស៊ើបអង្កេតលើបណ្តឹងរើសអើងឬការយាយី។ ជនណាដែលចូលរួមក្នុងការវាយប្រហារនឹង

ត្រូវទទួលទោសតាមវិន័យដែលបានចែង។
យើងក៏ហាមឃាត់ការចោទប្រកាន់មិនពិតអំពីការរើសអើង ឬការឃាយីផងដែរ។ ជនណាដែលធ្វើការចោតប្រកាន់មិនពិតនឹងត្រូវទទួលទោសតាមវិន័យដែលបានចែង។

*[ស្ថាប័ន]* នឹងផ្តល់ការបណ្តុះបណ្តាល និងការអប់រំដល់សិស្សានុសិស្ស និងបុគ្គលិកទាំងអស់អំពីគោលការណ៍នេះ និងអំពីរបៀបការពារ និងឆ្លើយតបចំពោះការរើសអើង និងការបៀតបៀន។ *[ស្ថាប័ន]* ក៏នឹងផ្សព្វផ្សាយគោលការណ៍នេះទៅកាន់មាតាបិតា និងអាណាព្យាបាលទាំងអស់ ព្រមទាំងដាក់បញ្ចូលវាលើគេហទំព័រវិបសាយរបស់សាលា និងនៅក្នុងសៀវភៅណែនាំរបស់សាលា។

*[ស្ថាប័ន]* ស្វាគមន៍រាល់មតិកែលម្អ ឬការផ្តល់យោបល់អំពីរបៀបកែលម្អគោលនយោបាយនេះ និងដើម្បីលើកកម្ពស់វប្បធម៌សាលាដែលប្រកបទៅដោយបរិយាបន្ន និងការគោរពគ្នាទៅវិញទៅមក។ យើងនឹងពិនិត្យមើលគោលការណ៍នេះជាប្រចាំ ហើយធ្វើការកែប្រែ ឬធ្វើបច្ចុប្បន្នភាពក្នុងករណីចាំបាច់។

## ៣.១.២ ការវាយតម្លៃទៅលើតម្រូវការផ្នែកសមត្ថភាពក្នុងការអនុវត្តបរិយាបន្ន

ជំហានសំខាន់មួយទៀតក្នុងការធ្វើផែនការបរិយាបន្នគឺការវាយតម្លៃគ្រឿងបរិក្ខារសម្ភារៈដែលមានស្រាប់ និងធនធានមនុស្សដើម្បីអនុវត្តការងារ។ វានឹងជួយស្ថាប័នដើម្បីកំណត់នូវអ្វីដែលមានស្រាប់ និងអ្វីដែលត្រូវកែសម្រួល ឬត្រូវស្ថាបនា។

### ៣.១.២.ក ហេដ្ឋារចនាសម្ព័ន្ធនិងការបង្កលក្ខណៈងាយស្រួលដែលមានស្រាប់

ជំហាននេះពាក់ព័ន្ធនឹងការវាយតម្លៃថាតើស្ថាប័ននោះបង្កលក្ខណៈងាយស្រួលបានដល់កម្រិតណា ដោយមានការគាំទ្រពីធនធានរបស់ស្ថាប័ន ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ (អគារ បន្ទប់រៀន បង្គន់អនាម័យ។ល។) ក៏ដូចជាផ្នែកព័ត៌មាន (អក្សរផុស ឬកម្មវិធីប្រូក្រាមសម្រាប់ជនមានពិការភាពភ្នែក និងភាសាសញ្ញាសម្រាប់ជនមានពិការភាពការស្តាប់) ។ តាមរយៈការវាយតម្លៃបែបនេះ វិទ្យាស្ថានបណ្តុះបណ្តាលនឹងយល់កាន់តែច្បាស់អំពីស្ថានភាពនៃការបង្កលក្ខណៈងាយស្រួលរបស់ពួកគេ ហើយអាចចាត់វិធានការចាំបាច់ដើម្បីកែលម្អវា។

**អ្វីដែលត្រូវពិនិត្យ**

- ❑ ទីធ្លាសម្រាប់ផ្លាស់ទីចេញចូល
- ❑ ឧបករណ៍ប្រើប្រាស់ក្នុងថ្នាក់រៀន៖ កៅអី តុ កន្លែងទំនេរ សម្ភារៈផ្សេងៗ
- ❑ បន្ទប់ទឹក៖ បង្គន់អនាម័យ កន្លែងទំនេរ
- ❑ ផ្លាកសញ្ញា និងទិសដៅប្រាប់ផ្លូវ
- ❑ កន្លែងស្នាក់នៅ
- ❑ អាហារដ្ឋាន
- ❑ ផ្លូវជម្លៀសបន្ទាន់ និងកណ្តឹងប្រកាសអាសន្ន
- ❑ ការដឹកជញ្ជូន

CZECH REPUBLIC DEVELOPMENT COOPERATION

PEOPLE IN NEED CZECH REPUBLIC

agile

**ធនធាន**

**<u>គោលការណ៍ណែនាំមិនមែនបច្ចេកទេសនៃការបង្កលក្ខណៈងាយស្រួល (KH & ENG) ៖</u>**

https://bit.ly/nontechnical-guideline ដែលបង្កើតឡើងដោយក្រុមប្រឹក្សាសកម្មភាពជនពិការ និងមនុស្សជាតិ និងបរិយាបន្ន (HI) អាចត្រូវបានប្រើជាមគ្គុទ្ទេសក៍វាយតម្លៃ។ គោលការណ៍នេះគឺជាបញ្ជីត្រួតពិនិត្យដែលត្រូវបានបង្កើតឡើងតាមជំហានទាំងបួននៃគោលការណ៍ RECU សម្រាប់ការបង្កលក្ខណៈងាយស្រួល (RECU: Reach, Entre, Circulate and Use) ហើយមិនត្រូវការឧបករណ៍ឯកទេស ឬជំនាញណាមួយឡើយ ប៉ុន្តែពឹងផ្អែកលើការសង្កេត។ វាអាចត្រូវបានធ្វើឡើងដោយនរណាម្នាក់ដែលមានចំណាប់អារម្មណ៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវការបង្កលក្ខណៈងាយស្រួលនៃបរិស្ថានរបស់ខ្លួន។ ការវាយតម្លៃគ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃការបង្កលក្ខណៈងាយស្រួលដូចជា (ផ្ដេក បញ្ឈរ ទាក់ទងនឹងការទំនាក់ទំនង) ហើយនៅពេលជាមួយគ្នានេះដែរ ក៏ផ្ដោតលើប្រភេទនៃឧបសគ្គផ្សេងៗគ្នា (ផ្ដេក បញ្ឈរ ទាក់ទងនឹងការទំនាក់ទំនង) សម្រាប់មនុស្សដែលមានពិការភាពប្រភេទផ្សេងៗគ្នា (រាងកាយ គំហើញ , ការស្ដាប់, ផ្លូវចិត្ត និងសតិបញ្ញា), មនុស្សចាស់, កុមារ, ស្ត្រីមានផ្ទៃពោះ។ល។

### ៣.១.២.ខ សមត្ថភាពបុគ្គលិក - តារាងពិន្ទុនៃបរិយាបន្នពិការភាព

ផ្នែកមួយនៃដំណើរការរៀបចំផែនការគឺការវាយតម្លៃពីអារម្មណ៍ ការយល់ឃើញ និងផ្នត់គំនិតនៃបរិយាបន្នពិការភាព។ ស្ថាប័នអាចសម្រេចវាបានតាមរយៈការស្ទង់មតិផ្លូវការដើម្បីទទួល

បានព័ត៌មាន (សូមមើលឧបសម្ព័ន្ធទី ២ សម្រាប់តារាងពិន្ទុរួមបញ្ចូលពិការភាព) ឬផ្តល់ឱ្យបុគ្គលិកដែលពាក់ព័ន្ធនូវច្បាប់ចម្លងនៃការណែនាំនេះ ហើយជជែកជាមួយពួកគេអំពីរបៀបដែលអ្នកនឹងបន្ត និងតួនាទីរបស់បុគ្គលម្នាក់ៗក្នុងការទទួលបានបរិយាបន្នពិការភាព។

## ៣.២. លើកទឹកចិត្តឱ្យមានការចូលរួម

### ៣.២.១ ការផ្សព្វផ្សាយ និងការជ្រើសរើសបុគ្គលិក



ការជ្រើសរើសសិក្ខាកាមមានពិការភាពទាមទារឱ្យស្ថាប័នជ្រើសរើសផ្តល់សារឱ្យបាន ច្បាស់លាស់។

